ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលសន្និបាតសុខាភិបាល លើកទី៤៥

នៅថ្ងៃទី២៦ និងថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦ ក្រសួងសុខាភិបាលបានរៀបចំសន្និបាតសុខាភិបាល លើកទី៤៥ ក្នុងគោលបំណងបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត ដើម្បីបន្តបោះជំហានទៅមុខដ៏សំខាន់ និងដាក់ចេញទិសដៅការងារសម្រាប់ការដឹកនាំ និងគ្រប់គ្រងវិស័យសុខាភិបាល សំដៅលើការអនុវត្តវិធានគន្លឹះក្នុងវិស័យសុខាភិបាល ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានអញ្ជើញជាអធិបតីក្នុងពិធីបើកសន្និបាត សុខាភិបាលដោយមានការអញ្ជើញចូលរួមពី** ថ្នាក់ដឹកនាំក្រសួងសុខាភិបាល មន្ត្រីរាជការសុខាភិបាលនៅថ្នាក់កណ្តាល អភិបាលរងរាជធានី-ខេត្ត សាលាមធ្យមសិក្សាបច្ចេកទេសសុខាភិបាលភូមិភាគ មន្ត្រីមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត មន្ទីរពេទ្យរាជធានី-ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព តំណាងក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងគណៈវិជ្ជាជីវៈសុខាភិបាលទាំង៥ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ កាកបាទក្រហមកម្ពុជា ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល សរុបចំនួន ៦៨០នាក់។ ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី បានអញ្ជើញដឹកនាំក្រុមពិភាក្សាលើប្រធានបទសំខាន់ៗ ក្នុងវិស័យសុខាភិបាល រួមមាន៖ ១)ជំងឺមិនឆ្លង និងសុខភាពផ្លូវចិត្ត ដោយបង្ហាញពីការបង្ការ ការគ្រប់គ្រងជំងឺមហារីក និងការគាំទ្រផ្លូវចិត្ត ក្នុងគ្រោះអាសន្នសុខភាពសាធារណៈ ២)សុខភាពមាតា ទារក និងកុមារ ដោយផ្តោតសំខាន់លើការកាត់បន្ថយមរណភាពមាតា និងទារក ត្រូវការកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងសុខាភិបាល អង្គភាពពាក់ព័ន្ធ និងសហគមន៍ ដើម្បីធានាថាមាតា និងទារក ទទួលបានសេវាថែទាំប្រកបដោយគុណភាព និងទាន់ពេលវេលា ៣)សុខភាពតែមួយ ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) គឺជាបញ្ហាសុខភាពសាធារណៈដែលទាមទារឱ្យមានការចូលរួមពីពហុវិស័យ និងពហុជំនាញ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងសុវត្ថិភាព នៃសេវាថែទាំ ព្យាបាល នៅគ្រប់មូលដ្ឋានសាធារណៈ និងឯកជន ៤)គុណភាពសេវាថែទាំសុខភាព និងសុវត្ថិភាពអ្នកជំងឺ ដោយផ្តោតទៅលើសសរស្តម្ភ ៤គឺ៖ ការលើកកម្ពស់ការថែទាំសុខភាពបឋម (PHC-BIF), ការពង្រឹងសុវត្ថិភាពអ្នកជំងឺ (Patient safety pathway), ការធានាគុណភាពសេវាសុខាភិបាល (Quality improvement) ដើម្បីបង្កើនទំនុកចិត្តពីសាធារណជន និងគោលការណ៍គ្រឹះនៃក្រមសីលធម៌វិជ្ជាជីវៈ និងក្រមសីលធម៌ ដែលជាគុណតម្លៃសកល (medical and moral ethics) ៥)បរិវត្តកម្មសុខាភិបាលឌីជីថល ដោយពិនិត្យផែនការគោល នៃប្រព័ន្ធសុខាភិបាលឌីជីថលក្នុងការផ្លាស់ប្តូរ ដើម្បីចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងយុគសម័យថ្មីសម្រាប់ការគាំទ្រវិស័យសុខាភិបាល។



អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩)
សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

អាយុជីវិតប្រជាពលរដ្ឋពីវិបត្តិសុខភាព ដែលបានកើតឡើង ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាចន្ទល់រឹងមាំមួយនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព។ ដូច្នេះ ត្រូវបន្តរក្សាភាពបុរេសកម្មនៃប្រព័ន្ធអង្កេតតាមដានជំងឺឆ្លងរាតត្បាត ឬគ្រោះអាសន្ន សុខភាពដទៃទៀត និងពង្រឹងយន្តការឆ្លើយតបឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព ព្រមទាំងត្រៀមនិងពង្រឹងប្រព័ន្ធផ្គត់ផ្គង់ចាំបាច់នានា និងប្រើបណ្តាញផ្សព្វផ្សាយពីប្រភពច្បាស់លាស់ ដើម្បីផ្តល់ព័ត៌មានទាន់បច្ចុប្បន្នហេតុ ត្រឹមត្រូវអាចជឿទុកចិត្តបានដល់សាធារណជន ជាពិសេស ដល់ប្រជាជន និងសហគមន៍ដែលមានហានិភ័យខ្ពស់។

៥. **ការចាប់យកការប្រើបច្ចេកវិទ្យាសុខាភិបាលឌីជីថល ដើម្បីពង្រឹងភាពធន់ និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល៖** ក្រសួងសុខាភិបាលត្រូវបន្តដំណើរបរិវត្តកម្មសុខាភិបាលឌីជីថល ក្នុងវិស័យសុខាភិបាល ដើម្បីកសាងប្រព័ន្ធអេកូសុខាភិបាលឌីជីថលមួយ ប្រកបដោយថាមវន្ត និងមានចីរភាព ដែលផ្តោតលើប្រជាជន និងផ្អែកលើមូលដ្ឋានច្បាប់ លិខិតបទដ្ឋានគតិយុត្ត ស្តង់ដា និងក្រមសីលធម៌ ដើម្បីកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋ និងសាធារណជន តាមរយៈការបម្រើ សេវាថែទាំសុខភាព សេវាពាក់ព័ន្ធ និងអន្តរាគមន៍សុខភាពសាធារណៈ ឱ្យកាន់តែប្រសើរឡើង សំដៅចូលរួមកសាងពលរដ្ឋឌីជីថល កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើកនៅកម្ពុជា។

៦. ក្រសួងសុខាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវអនុវត្ត និងបន្តអនុវត្ត បទបញ្ជា០១ និង០២ប.ប លើអ្នកញៀនគ្រឿងញៀន ដែលជាវិធានការមានសារៈសំខាន់ ក្នុងការការពារសុខុមាលភាពសាធារណៈ និងការទប់ស្កាត់បញ្ហាគ្រឿងញៀនក្នុងសង្គម ដើម្បីធានាថា ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ និងមានប្រសិទ្ធភាព។

ជាចុងក្រោយ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី** បានសម្តែង និងកោតសរសើរ ចំពោះថ្នាក់ដឹកនាំក្រសួងសុខាភិបាល រដ្ឋបាលរាជធានី ខេត្ត មន្ត្រីរាជការសុខាភិបាល គ្រូពេទ្យ បុគ្គលិកនៅតាមប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកគ្រប់កម្រិត ព្រមទាំងមន្ត្រី បុគ្គលិកជំនាញសុខភាពសាធារណៈ ដែលបានយកចិត្តទុកដាក់ ខិតខំបំពេញការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ជាពិសេសក្នុងការការពារសុខភាព និងការបម្រើសេវាថែទាំ ព្យាបាល ជូនបងប្អូនប្រជាពលរដ្ឋភៀសសឹក និងវីរកងទ័ពយើងនៅក្នុងកាលៈទេសៈនៃជម្លោះព្រំដែនកម្ពុជា-ថៃ។

ថ្ងៃសុក្រ ១២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦

ទី៤. **ការបន្តពង្រឹងភាពធន់ប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិ ក្នុងការត្រៀមខ្លួន និងការឆ្លើយតបរហ័ស ប្រកបដោយប្រសិទ្ធភាព នឹងការគម្រាមកំហែងសុខភាព ឬគ្រោះអាសន្នសុខភាព។** ការសម្រេចបានភាពធន់នៃប្រព័ន្ធសន្តិសុខសុខភាពជាតិ អាស្រ័យមួយភាគធំលើភាពធន់ នៃប្រព័ន្ធសុខាភិបាលស្រុកប្រតិបត្តិ ដែលជាកំផែងទីមួយ ក្នុងការការពារអាយុជីវិតប្រជាជន ដែលរស់នៅក្នុងសហគមន៍។ ក្នុងន័យនេះ យើងចាំបាច់ត្រូវបង្កើនការយកចិត្តទុកដាក់ថែមទៀតដល់ការពង្រឹងសមត្ថភាពត្រៀម និងឆ្លើយតបរបស់ស្រុកប្រតិបត្តិ ចំពោះគ្រប់ទម្រង់នៃការគម្រាមកំហែងសុខភាពសាធារណៈ ដោយត្រូវបន្តពង្រឹងកិច្ចដំណើរការពេញលេញនៃប្រព័ន្ធគ្រប់គ្រងឧប្បត្តិហេតុ និងមណ្ឌលប្រតិបត្តិការសម្រាប់គ្រោះអាសន្ន នៅគ្រប់ស្រុកប្រតិបត្តិ ព្រមទាំងរក្សាចីរភាពទំនាក់ទំនងទាន់ហេតុការណ៍ នៅទូទាំងប្រព័ន្ធគ្រប់គ្រង ឧប្បត្តិហេតុ រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតសុខាភិបាលលើកទី៤៥។ ក្នុងពិធីបិទ **ឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍សំខាន់មួយចំនួន ដល់អង្គសន្និបាត ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព តាមតួនាទី និងភារកិច្ចរបស់ស្ថាប័ន នូវកិច្ចការជាអាទិភាពមួយចំនួនរួមមាន៖

១. **បន្តជំរុញវឌ្ឍនភាព ឆ្ពោះទៅសម្រេចគោលដៅគ្របដណ្តប់សុខភាពជាសកល និងការលើកកម្ពស់សមធម៌៖** ត្រូវបន្តពង្រឹងការផ្តល់សេវាថែទាំសុខភាព នៅក្នុងប្រព័ន្ធប្រតិបត្តិការ គាំពារសុខភាពសង្គម ដើម្បីកាត់បន្ថយគម្លាតនៃការទទួលបានសេវាថែទាំសុខភាព ដែលមានគុណភាពរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ និងបង្កើនការទទួលបានសេវាថែទាំសុខភាព នៅពេលត្រូវការរបស់គ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ។

២. **ពង្រឹងការថែទាំសុខភាពបឋម៖** ត្រូវបន្តជំរុញតួនាទីមន្ទីរពេទ្យបង្អែក ក្នុងការពង្រឹងសេវា ថែទាំសុខភាពបឋម ជាពិសេស ការអប់រំលើកកម្ពស់សុខភាព និងការបង្ការជំងឺ ដោយបញ្ជ្រាប ការថែទាំសុខភាពបឋមទៅក្នុងការផ្តល់សេវានៅមន្ទីរពេទ្យ និងផ្តល់ការគាំទ្របច្ចេកទេសដល់ មណ្ឌលសុខភាពក្នុងការកែលម្អគុណភាព និងការពង្រីកការគ្របដណ្តប់នៃសេវា តាមរយៈអភិបាលកិច្ចគាំទ្រ ការបណ្តុះបណ្តាល ការពង្រឹងប្រព័ន្ធបញ្ជូន និងការសម្របសម្រួលការថែទាំ រវាងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។

៣. **ការធ្វើទំនើបកម្ម និងនវានុវត្តន៍សេវាថែទាំព្យាបាល៖** ត្រូវបន្តពង្រឹងមន្ទីរពេទ្យខេត្តឱ្យមានសមត្ថភាពបច្ចេកទេស និងជំនាញឯកទេសកាន់តែខ្ពស់ ក្នុងការធ្វើរោគវិនិច្ឆ័យ និងការថែទាំ ព្យាបាល ខណៈដែលមន្ទីរពេទ្យជាតិទាំងអស់ ត្រូវបន្តធ្វើនវានុវត្តន៍សមត្ថភាពជំនាញ ឱ្យកាន់តែទូលំទូលាយ និងប្រកបដោយឧត្តមានុភាព ដើម្បីឆ្លើយតបនឹងតម្រូវការថែទាំ និងព្យាបាលរបស់ ប្រជាពលរដ្ឋ និងកាត់បន្ថយជាអតិបរមាការទៅរកសេវានៅក្រៅប្រទេស។ គុណភាព សុវត្ថិភាព និងស័ក្តិសិទ្ធភាពនៃសេវា ព្រមទាំងតម្លៃសមរម្យ គឺជាកត្តាចម្បងនៃការកសាងទំនុកចិត្តរបស់ប្រជាពលរដ្ឋ មកលើប្រព័ន្ធសុខាភិបាលកម្ពុជា។

៤. **ពង្រឹងសមត្ថភាពត្រៀម និងឆ្លើយតបទាន់ពេល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពចំពោះការគំរាមកំហែងសុខភាព និងស្តារស្ថានការណ៍ឡើងវិញឆាប់រហ័ស ក្រោយវិបត្តិកើតឡើង៖** មិនគ្រាន់តែការពារ

នៅឆ្នាំ២០២៦ និងឆ្នាំបន្ត ក្រសួងសុខាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពសុខាភិបាល ទូទាំងប្រទេសនឹងបន្តចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ជាពិសេសកម្មវិធីគោលនយោបាយ អាទិភាពទី១ ការពង្រីកសេវាសុខាភិបាលឆ្ពោះទៅកាន់ការគ្របដណ្តប់សុខភាពជាសកល និងការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល និងផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៣ ដោយផ្តោតលើអន្តរាគមន៍ ជាអាទិភាពចម្បងៗរួមមាន៖

**ទី១. ការសម្រេចគោលដៅសុខភាពក្នុងវិស័យសុខាភិបាល នៅក្នុងឆ្នាំ២០២៦ និងឆ្នាំខាងមុខ ឱ្យបានតាមកាលកំណត់ ប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។** ឆ្នាំ២០៣០ គឺជាឆ្នាំដែលកម្ពុជានឹងធ្វើសេចក្តីសន្និដ្ឋានអំពីសមិទ្ធកម្មនៃ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ហើយក៏ជាឆ្នាំពាក់កណ្តាលនៃក្របខ័ណ្ឌពេលវេលានៃការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤ ផងដែរ។ ដូច្នេះ អង្គភាពសុខាភិបាលគ្រប់លំដាប់ថ្នាក់ ត្រូវពិនិត្យមើលឡើងវិញ ឱ្យបានម៉ត់ចត់នូវនិន្នាការ និងកម្រិតវឌ្ឍនភាពនៅឆ្នាំ២០២៥ នៃសូចនាករសមិទ្ធកម្មគន្លឹះ និងសូចនាករដទៃទៀត ដែលពាក់ព័ន្ធតួនាទី និងភារកិច្ចរបស់អង្គភាព ហើយត្រូវធ្វើអាទិភាវូបនីយកម្មអន្តរាគមន៍ ឬសកម្មភាពដែលត្រូវអនុវត្ត ស្របតាមទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត ដើម្បីពន្លឿនវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍ ប្រកបដោយចីរភាព ទាក់ទងសុខភាព និងគោលដៅនៃផែនការយុទ្ធសាស្ត្រសុខាភិបាល ដែលបានកំណត់សម្រាប់ឆ្នាំ២០៣០។

**ទី២. ការពង្រឹងអនុលោមភាពនិយ័តកម្ម និងការទទួលយកបានគុណភាពសេវាថែទាំសុខភាព ពីសំណាក់ប្រជាពលរដ្ឋ។** ខណៈដែលយន្តការតាមដានវាយតម្លៃ និងលើកកម្ពស់គុណភាពសេវានៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈកំពុងបន្តពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ការបង្កើតប្រព័ន្ធទទួលស្គាល់គុណភាពសេវាថែទាំសុខភាពនៅកម្ពុជា សកម្មភាពតាមដានវាយតម្លៃ **គុណភាព និងសុវត្ថិភាពអ្នកជំងឺ នៅក្នុងទិដ្ឋភាពគ្លីនិក**នៃការថែទាំព្យាបាល ជាពិសេសនៅមន្ទីរពេទ្យ និងគ្រឹះស្ថានផ្តល់សេវាថែទាំព្យាបាលឯកជន ត្រូវផ្សាភ្ជាប់ជាមួយសកម្មភាពអភិបាលកិច្ចគ្លីនិក ដើម្បីលើកស្ទួយគណនេយ្យភាពរបស់អ្នកផ្តល់សេវាលើគុណភាព និងសុវត្ថិភាពសេវាដែលបានផ្តល់ជូនអ្នកជំងឺ ឬអ្នកប្រើប្រាស់ ស្របតាមបទដ្ឋានស្តង់ដាបច្ចេកទេស ឬពិធីសារគ្លីនិក និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ទី៣. ការពង្រឹងយន្តការតាមដាន និងវាយតម្លៃសុវត្ថិភាពអ្នកជំងឺជាប្រចាំ នៅក្នុងមន្ទីរពេទ្យ ដើម្បីបង្កើនទំនុកចិត្ត ពីប្រជាជនមកលើប្រព័ន្ធផ្តល់សេវាថែទាំសុខភាព។** យើងត្រូវបន្តពង្រឹងយន្តការដែលមានលក្ខណៈជាប្រព័ន្ធ សម្រាប់តាមដាន និងលើកកម្ពស់សុវត្ថិភាពគ្លីនិកអ្នកជំងឺ ដែលនៅមិនទាន់ដំណើរការពេញលេញ ឱ្យមានសង្គតិភាពជាមួយគោលនយោបាយ ឬនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីគុណភាព និងសុវត្ថិភាពនៃការថែទាំព្យាបាល ក្នុងនោះរួមមាន ប្រព័ន្ធរាយការណ៍ពីឧប្បត្តិហេតុសុវត្ថិភាពក្នុងការថែទាំព្យាបាល និងការចេញវេជ្ជបញ្ជា រួមទាំងការកំណត់សូចនាករគន្លឹះសម្រាប់ការវាយតម្លៃការប្រៀបធៀបសមិទ្ធកម្ម និងការវាស់វែងអនុលោមភាពនៃការ អនុវត្តស្តង់ដា ដើម្បីតម្រង់ទិសអ្នកវិជ្ជាជីវៈសុខាភិបាលឱ្យផ្តល់សេវាផ្តោតលើអ្នកជំងឺ ផ្អែកលើភស្តុតាងវេជ្ជសាស្ត្រ និងមានសង្គតិភាពជាមួយគោលដៅគ្លីនិក។